# មជ្ឈមណ្ឌលឯកសារកម្ពុជា

**BMI0026**

## សម្ភាសន៍ជាមួយឈ្មោះ សុង ឡាំង ភេទប្រុស អាយុ៥៣ឆ្នាំ

មុខងារជំនាន់ខ្មែរក្រហម“កងចល័ត”

មុខងារបច្ចុប្បន្ន“កសិករ”

ស្រុកកំណើតនៅភូមិតាគង់ ឃុំពុកតាសត ស្រុកសេរីសោភ័ណ្ឌ ខេត្តបាត់ដំបង

រស់នៅភូមិវត្តចាស់ ឃុំម៉ាឡៃ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ

ថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១០

សម្ភាសន៍ដោយៈ សុខ វណ្ណៈ

០១:០៥:១៣

២៩ទំព័រ

វណ្ណៈ ជាដំបូងខ្ញុំសូមណែនាំខ្លួនថាខ្ញុំឈ្មោះសុខ វណ្ណៈមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា ។

ឡាំង ៖ បាទ ។

វណ្ណៈ ខ្ញុំមកនេះចឹងដឹងរឿងរ៉ាវនៅក្នុងស្រុកម៉ាឡៃហ្នឹង ចង់ដឹងពីជំនាន់ខ្មែរក្រហមរហូតមកដល់បច្ចុប្បន្ន ថាតើមានរឿងរ៉ាវអ្វីកើតឡើងខ្លះ?

ឡាំង ៖ បាទ ។

វណ្ណៈ មានលក្ខណៈខុសប្លែកគ្នាយ៉ាងម៉េច?

ឡាំង ៖ បាទ ។

វណ្ណៈ ខ្ញុំចង់បានរឿងរ៉ាវទាំងអស់ហ្នឹងយកទៅសរសេរជាសៀវភៅ ដើម្បីឲ្យកូនក្មេងជំនាន់ក្រោយហ្នឹង បានដឹងបានឮថា ពីមុនស្រុកម៉ាឡៃវាចេះ ឥឡូវវាចេះមានផ្លូវជាតិមានអីចឹង ហើយ១០ទៅ ២០ទៅ៣០ឆ្នាំទៀតម៉ាឡៃទៅជាយ៉ាងម៉េចវិញ ។ ចឹងយើងចង់ដឹងពីម៉ាឡៃដែលមានប្រវត្តិ កកើតឡើងដើម្បីឆ្លុះបញ្ចាំងឲ្យក្មេងៗបានដឹងបានឮណាពូណាស់ ។

ឡាំង ៖ បាទ ។

វណ្ណៈ ចឹងព័ត៌មានដែលខ្ញុំបានសម្ភាសន៍ជាមួយពូហ្នឹង តើពូអាចឲ្យខ្ញុំយកទៅសរសេរជាសៀវភៅឲ្យក្មេង ជំនាន់ក្រោយបានដឹងបានឮតើពូអនុញ្ញាតទេ?

ឡាំង ៖ ទេ អាហ្នឹងស្រេចតែខាងហ្នឹងចុះ ។

វណ្ណៈ បាទ! ចឹងពូមិនថាអីទេ បទសម្ភាសន៍ដែលខ្ញុំជាមួយពូហ្នឹងអាចឲ្យយកជាព័ត៌មានបាន?

ឡាំង ៖ បាទ ។

វណ្ណៈ  ចឹងពូឈ្មោះអីដែរ?

ឡាំង ៖ ឈ្មោះសុង ឡាំង ។

វណ្ណៈ  ត្រកូលអីគេទៅ?

ឡាំង៖  ត្រកូលសុង ឡាំង ។

វណ្ណៈ  ពូអាយុប៉ុន្មានហើយ?

ឡាំង ៖ អាយុ៥១ ។

វណ្ណៈ  ប្រពន្ធពូ?

ឡាំង ៖ ប្រពន្ធឈ្មោះ ឌឹម យ៉ឹម ។

វណ្ណៈ  គាត់អាយុប៉ុន្មាន?

ឡាំង ៖ ៤១ ។

វណ្ណៈ  ពូមានកូនប៉ុន្មាននាក់?

ឡាំង ៖ មានកូន៤នាក់ ។

វណ្ណៈ  ស្រីប៉ុន្មានប្រុសប៉ុន្មាន?

ឡាំង ៖ សុទ្ធតែប្រុសទាំងអស់ ។

វណ្ណៈ  ចឹងឪពុកពូឈ្មោះអីដែរ?

ឡាំង ៖ ឪពុកខ្ញុំបង្កើតហ្នឹងខ្ញុំដាក់នាមត្រកូលឪពុកខ្ញុំហ្នឹងហើយ ។

វណ្ណៈ  គាត់ឈ្មោះអី?

ឡាំង៖  គាត់ឈ្មោះសុងហ្នឹងហើយ ។

វណ្ណៈ  គាត់ឈ្មោះសុង?

ឡាំង ៖ បាទ!ឈ្មោះ សុងហ្នឹងហើយ ខ្ញុំប្រើនាមត្រកូលយាយខ្ញុំហ្នឹងឈ្មោះនេះទេ ឈ្មោះគេហៅតា សូរៗទេ សូរហ្នឹងគេហៅសូរ សុផាហ្នឹងណាស់ ។

វណ្ណៈ  ចឹងឪពុកពូឈ្មោះសុង?

ឡាំង ៖ បាទ ។

វណ្ណៈ  ចឹងត្រកូលគាត់សូរ?

ឡាំង៖  សូរ សុផា ប្រពន្ធគាត់ឈ្មោះផាណាស់ ។

វណ្ណៈ  ចឹងខ្ញុំសួរឪពុកពូសិន ឪពុកពូឈ្មោះ?

ឡាំង៖  សុង ។

វណ្ណៈ  សុង?

ឡាំង៖ បាទ ។

វណ្ណៈ ចឹងសួរ សុង?

ឡាំង៖ បាទ ។

វណ្ណៈ ចឹងម្ដាយពូឈ្មោះអី?

ឡាំង៖ ឈ្មោះ ឡៃ ។

វណ្ណៈ ចឹងត្រកូលគាត់ឈ្មោះអីឡៃទៅ?

ឡាំង៖ ត្រកូលគាត់ឈ្មោះ គេហៅសុផា ឡៃហ្នឹងហើយ ។

វណ្ណៈ សុផា ឡៃ?

ឡាំង៖ បាទ ។

វណ្ណៈ ចឹងគាត់ទាំងពីរសព្វថ្ងៃនៅរស់ដែលឬយ៉ាងម៉េច?

ឡាំង៖ គាត់អត់មាននៅរស់ផងផាប់ហើយ ។

វណ្ណៈ គាត់ស្លាប់ដោយសារអី?

ឡាំង ៖ ស្លាប់ដោយសារជំងឺ ។

វណ្ណៈ ជំនាន់ណា?

ឡាំង ៖ ជំនាន់ឥឡូវហ្នឹងប្រហែលជា១០ឆ្នាំជាង តែឪខ្ញុំស្លាប់យូរហើយតាំងពីខ្ញុំមិនទាន់ដឹងក្ដី ។

វណ្ណៈ ចឹងម្ដាយស្លាប់ឥឡូវតែឪពុកស្លាប់យូរហើយ?

ឡាំង៖ ឪពុកស្លាប់យូរហើយ ។

វណ្ណៈ ចឹងពូមានបងប្អូនបង្កើតប៉ុន្មាននាក់?

ឡាំង ៖ ខ្ញុំមានបងប្អូនបង្កើតទាំងអស់៨នាក់ ។

វណ្ណៈ ស្រីប៉ុន្មានប្រុសប៉ុន្មាន?

ឡាំង ៖ ប្រុសតែខ្ញុំម្នាក់ ។

វណ្ណៈ ចឹងសព្វថ្ងៃបងប្អូនពូរស់នៅជុំគ្នាឬយ៉ាងណា?

ឡាំង ៖ បងប្អូនខ្ញុំរស់នៅខាងស្វាយសព្វថ្ងៃ ។

វណ្ណៈ នៅស្វាយទាំងអស់?

ឡាំង៖ នៅស្វាយតែពីរនាក់ទេ មកនៅតាគង់ភូមិចាស់ហ្នឹងម្នាក់ ។

វណ្ណៈ ចឹងនៅជំនាន់ខ្មែរក្រហមអត់មានបាត់បង់ទេ?

ឡាំង ៖ នៅរស់ទាំងអស់ ។

វណ្ណៈ ចឹងពូមានស្រុកកំណើតនៅណា?

ឡាំង ៖ ខ្ញុំនៅតា គង់ហ្នឹងតែម្ដង នៅភូមិតា គង់ហ្នឹងតែម្ដង ។

វណ្ណៈ ភូមិតាគង់?

ឡាំង៖ បាទ ។

វណ្ណៈ ឃុំ?

ឡាំង៖ ឃុំកាលនោះគេដាក់ឃុំពុតតាសត ។

វណ្ណៈ ឃុំពុត?

ឡាំង៖ ឃុំពុតតាសត ។

វណ្ណៈ ពុតតាសត?

ឡាំង៖ បាទ ។

វណ្ណៈ ស្រុក មិនមែនម៉ាឡៃទេ?

ឡាំង៖ អត់ទេ កាលនោះស្រុកពកធំ ។

វណ្ណៈ បាទ?

ឡាំង៖ ភូមិពកធំនេះណាស់ ផ្លូវចូលមកហ្នឹងណាស់ ។

វណ្ណៈ ស្រុកស្អីគេស្រុកមង្គលបូរីឬស្រុកអី?

ឡាំង៖ ស្រុកកាលនោះ ។

វណ្ណៈ បាទ ។

ឡាំង៖ ស្រុកកាលនោះគេហៅស្រុកស្អីកន្ទែងស្វាយយើងណាស់ សេរីសោភ័ណ្ឌ ។

វណ្ណៈ សេរីសោភ័ណ្ឌ?

ឡាំង៖ បាទ ។

វណ្ណៈ ខេត្ត?

ឡាំង ៖ ខេត្តបាត់ដំបងជំនាន់នោះណាស់ ។

វណ្ណៈ ចឹងបច្ចុប្បន្ននៅឃុំណា?

ឡាំង ៖ បច្ចុបន្ននៅម៉ាឡៃ ។

វណ្ណៈ នៅភូមិ?

ឡាំង៖ ភូមិវត្តចាស់ ។

វណ្ណៈ ចឹងនៅហ្នឹងគេហៅវត្តចាស់?

ឡាំង៖ បាទ ។

វណ្ណៈ ឃុំ?

ឡាំង:   ឃុំម៉ាឡៃដែរ ។

វណ្ណៈ   ស្រុកម៉ាឡៃ?

ឡាំង:   បាទ ។

វណ្ណៈ   សព្វថ្ងៃពូប្រកបមុខរបរអ្វីដែរ?

ឡាំង : ធ្វើស្រែនិងចំការ ។

វណ្ណៈ   ចឹងខ្ញុំចង់ដឹងថា  ពេលវៀតណាមវ៉ៃចូលមកដល់ភ្នំពេញនៅឆ្នាំ១៩៧៩  ពូមកនៅណាបុធ្វើអីនៅណា?

ឡាំង:   កាលជំនាន់ហ្នឹងខ្ញុំនៅកងចល័ត ។

វណ្ណៈ   ៧៩?

ឡាំង : កាល៧៩ខ្ញុំរត់ចូលមកព្រំដែនហ្នឹង ។

វណ្ណៈ   រត់ដោយសារអី?

ឡាំង : រត់ដោយសារយួនដេញពីហ្នឹងមក ។

វណ្ណៈ   បាទ ។

ឡាំង : កាលនោះគេឃោសនាថាមិនបានទេ  តែយួនចូលមកអាកហ្នឹងធាងគ្នោតហើយចឹងក៏នាំគ្នារត់មកចាញ់ឃោសនាគេហ្នឹងណាស់ ។

វណ្ណៈ   ចឹងមកដល់ព្រំដែនម៉ាឡៃហ្នឹងតែម្តង ។

ឡាំង : បាទ ។

វណ្ណៈ   ចឹងម៉ាឡៃតាំងពី៧៩-៨០-៨១អីហ្នឹងដំបូងតំបន់ហ្នឹងពូឃើញយ៉ាងម៉េចដំបូងមានភូមិមានឃុំមានផ្ទះចឹងទេ?

ឡាំង : អត់មានទេ មានតែភូមិចាស់មានដើមដូងពីរទៅបីដើមចឹងទៅ គេហៅភូមិដូងបណ្តោយពីមុន ។

វណ្ណៈ   កាលដំបូងឡើងគេប្រមូលកំលាំងទ័ពអីយ៉ាងម៉េចដែរ?

ឡាំង : កាលនោះមានតែកំលាំងខ្មែរក្រហមទេ ។

វណ្ណៈ   កាលហ្នឹងកាលហ្នឹងគេប្រមូលទ័ពអីយ៉ាងម៉េចប្រមូលកំលាំងអីយ៉ាងម៉េចមានកំលាំងមកពីខាងណាខ្លះទេ?

ឡាំង:   កាលហ្នឹងមានតែកំលាំងខ្មែរក្រហម ។

វណ្ណៈ   ចឹងមានតែកំលាំងខ្មែរក្រហម?

ឡាំង:   បាទ ។

វណ្ណៈ   កាលហ្នឹងមេបញ្ជាការពីណាគេ កាល៧៩-៨០-៨១-៨២-៨៣អី?

ឡាំង ៖ កាលហ្នឹងមានច្រើន មេបញ្ជាការខ្ញុំមានពីរបីនាក់នោះ តែគាត់ស្លាប់អស់ហើយ ។

វណ្ណៈ  មេបញ្ជាការជាន់ខ្ពស់?

ឡាំង ៖ មេបញ្ជាការជាន់ខ្ពស់មានលោកសុខ ភាពនិងនាមត្រកូលគាត់ឈ្មោះអីទេ តា ហុងមួយទៀត ។

វណ្ណៈ  ចឹងកាលហ្នឹងគាត់ជាប្រធានកងពល?

ឡាំង ៖ ប្រធានកងពលឈ្មោះហុងតែម្តង តែខ្ញុំភ្លេចត្រកូលរបស់គាត់ ។

វណ្ណៈ  ចឹងសុខ ភាពលើប្រធានកងពលទៀត?

ឡាំង៖  សុខ ភាពហ្នឹងកាលជំនាន់ហ្នឹង ឈ្មោះ ហុងហ្នឹងលើសុខ ភាពហ្នឹងទៀត ។

វណ្ណៈ  ចឹង?

ឡាំង ៖ បាទ! លោកសុខ ភាពហ្នឹងគាត់ឡើងឆ្នាំប៉ុន្មានទេ ។

វណ្ណៈ  មើលនៅហ្នឹងមុនដំបូងគ្រប់គ្រងដោយលោកតា អៀង សារីមែនទេ?

ឡាំង ៖ បាទ ។

វណ្ណៈ  ចឹងប្រធានកងពលដំបូងឈ្មោះ ហុង?

ឡាំង៖  បាទ ។

វណ្ណៈ  ហ្នឹង៧៩?

ឡាំង៖  ៧៩ ។

វណ្ណៈ  ចឹងសុខ ភាពឡើងឆ្នាំណា?

ឡាំង៖  មិនដឹងជាឆ្នាំប៉ុន្មានទេ វេងសាខាគាត់ហ្នឹងណាស់ ។

វណ្ណៈ  ចឹងពូដូចថានៅខាងហ្នឹងបន្ទាប់ដូចថាប្រធានកងពលមកគេបែងចែកជាប៉ុន្មានដល់ថ្នាក់ក្រោម មានប៉ុន្មានវរៈទៀត?

ឡាំង៖ មកកងពលបានឡើងមក ។

វណ្ណៈ  ឧបមាថាឥឡូវប្រធានកងពលធំជាងគេហើយណាស់?

ឡាំង៖  បាទ ។

វណ្ណៈ  ចឹងចុះពីកងពលមកគេហៅអី?

ឡាំង ៖ មានវរៈសេនាធំ ។

វណ្ណៈ  វរៈសេនាធំហ្នឹងពីណាដឹកនាំ?

ឡាំង ៖ ដឹកនាំដោយលោកកាលនោះលោកនឿន ។

វណ្ណៈ  ចឹងអត់ស្គាល់នាមត្រកូលទេ?

ឡាំង៖  បាទ ។

វណ្ណៈ   ចឹងកាលហ្នឹងមានប៉ុន្មានវរៈសេនាធំ?

ឡាំង ៖ មានបីវរៈសេនាធំ ។

វណ្ណៈ   ចឹងវរៈសេនាតូចមានប៉ុន្មានទៀត?

ឡាំង ៖ វរៈសេនាតូចមានប៉ុន្មានទេ ខ្ញុំមិនសូវដឹងដែរ ។

វណ្ណៈ   ចឹងប្រធានវរៈស្គាល់តែលោកនឿនមួយទេមានស្គាល់ពីណាខ្លះទេ?

ឡាំង ៖ មានឈ្មោះ នឿនមានលោកមោង ។

វណ្ណៈ   មោង?

ឡាំងៈ   បាទ ។

វណ្ណៈ   មានពីណាទៀត?

ឡាំង ៖ លោកង៉ុន ។

វណ្ណៈ   ចឹងនឿនហ្នឹងគាត់កាន់វរៈសេនាធំលេខប៉ុន្មាន?

ឡាំង ៖ លេខ១៧អះ!លេខ១០៧ ។

វណ្ណៈ   ចឹងមោង?

ឡាំងៈ  ហ្នឹងរួមសាខាហ្នឹង ។

វណ្ណៈ   ចឹងមានបីវរៈនោះ?

ឡាំង ៖ ខាងវរៈគេផ្សេងខ្ញុំផ្សេង វរៈ១០៨ផ្សេង ។

វណ្ណៈ   ចឹងមោងហ្នឹងកាន់១០៨?

ឡាំងៈ   ហ្នឹងហើយ ។

វណ្ណៈ  ចឹងង៉ុនហ្នឹងកាន់១០០ប៉ុន្មាន?

ឡាំងៈ   ង៉ុនហ្នឹងមិនដឹងជា១០០ប៉ុន្មានទេ គេនៅសាខាផងគេហ្នឹងឯង ។

វណ្ណៈ   ចឹងមាន១០៧-១០៨-១០៩ឬយ៉ាងម៉េច?

ឡាំង ៖ មាន១០៧-១០៨និង១០៦ ។

វណ្ណៈ   ចឹងមានត្រឹមប៉ុណ្ណឹង?

ឡាំងៈ   បាទ ។

វណ្ណៈ   ហើយមានវរៈទៀត?

ឡាំងៈ   បាទ ។

វណ្ណៈ   ចឹងពូដូចថាយើងប្រមូលកំលាំងពូបានហ្នឹងមួយវរៈសេនាធំមានគ្នាប៉ុន្មាននាក់ទៅ?

ឡាំង ៖ មានជិត២០០នាក់ដែរ ។

វណ្ណៈ ចឹងមាន២០០នាក់?

ឡាំង: បាទ ។

វណ្ណៈ ចឹងនៅពេលដែលប្រមូលកំលាំងបានចឹងយើងធ្វើការបែងចែកគ្នាវើជាមួយខាងរដ្ឋាភិបាលយើង វើរបៀបយ៉ាងម៉េចពូ?

ឡាំង : វើជាក្រុម១ វើរបៀបវើឆ្នក់ ហើយវើកន្រ្ទាក់មីន ។

វណ្ណៈ ចឹងមានវើឆ្នក់និងវើកន្រ្ទាក់មីន?

ឡាំង: បាទ ។

វណ្ណៈ ហើយមានស្លាប់រស់អីជាការធម្មតាមានទៅមានមក?

ឡាំង : ជារឿងធម្មតាយើងសាចទឹកដាក់គ្នាហើយ ។

វណ្ណៈ ចឹងកាលហ្នឹងពូគិតមើលមានឈឺដោយសាគ្រុនចាញ់ស្លាប់នៅក្នុងព្រៃកាលហ្នឹងមានទេ កាលហ្នឹងខ្មែរក្រហម?

ឡាំង : មាន ។

វណ្ណៈ គ្រុនចាញ់ស្លាប់ដោយសារអីដែរ?

ឡាំង : ដោយសាកាលជំនាន់ហ្នឹងយើងអត់មានបាយ យើងចាញ់ហើយអត់មានថ្នាំលេបលិចកើតទៅ អត់បាយលិចកើតទៅស្លាប់ចឹងទៅ ។

វណ្ណៈ ចឹងអត់មានកន្លែងជ្រក?

ឡាំង: បាទ ។

វណ្ណៈ ដេកក្នុងព្រៃសុទ្ធ?

ឡាំង : នៅក្នុងព្រៃតែគេធ្វើជាខ្ទមមួយ១នៅមួយក្រុម១ចឹងទៅ ។

វណ្ណៈ ចឹងធ្វើជាជំរំ?

ឡាំង: បាទ ។

វណ្ណៈ ចឹងខាងខ្មែរក្រហមបានសម្ភារមកពីខាងណា?

ឡាំង : មិនដឹងជាមកពីខាងណាខ្លះទេ គេថាមកពីចិន ។

វណ្ណៈ មានកាំភ្លើងអីហ្នឹង.?

ឡាំង : បាទ ។

វណ្ណៈ ចឹងកាលពូធ្វើកងទ័ពហ្នឹងជីវភាពទ័ពឬអ្នកដែលរស់នៅក្នុងហ្នឹងគេខត្តម្តឲ្យហូបចុកបរបូរដែលឬអត់ ឬយ៉ាងម៉េច?

ឡាំង ៖ មានអីសម្បូរតើ គេចែកឲ្យទាំងអស់មានអង្ករ ស្ករស ប៊ីចេង ប្រហុកដូចជាទឹកត្រីហ្នឹងគេចែកឲ្យទាំងអស់ ។

វណ្ណៈ ចឹងគ្រប់គ្រាន់?

ឡាំង ៖ បាទ ។

វណ្ណៈ ចឹងប្រពន្ធកូននៅទីនេះដែលឬអត់ទេឬមួយនៅលើដីថៃ?

ឡាំង ៖ ប្រពន្ធកូនកាលនោះនៅដីថៃ នៅដីថៃមួយរយៈប្រហែលជាពីរឆ្នាំទៅបីឆ្នាំ ។

វណ្ណៈ ចឹងពូហេតុអីបានជាប្រទេសថៃឲ្យខាងខ្មែរក្រហមជ្រកកោនបានកាលហ្នឹងពូមានដឹងទេ ដូចថាយើងវៃចាញ់ខាងនេះចឹងយើងរត់ទៅខាងថៃ?

ឡាំង ៖ តាមខ្ញុំគិតថា ថៃមួយរយៈហ្នឹងថៃវាឲ្យជ្រកព្រោះថៃវាបានជំនួយពីខ្មែរក្រហមច្រើនណាស់ ។

វណ្ណៈ ចឹងណាស់?

ឡាំង ៖ បាទ ។

វណ្ណៈ ចឹងជំនួយជាស្អីគេ?

ឡាំង ៖ ជំនួយដូចជាគ្រាប់រំសេវវាយករបស់យើងចង់ពាក់កណ្តាល ដូចជាជំនួយរបស់ចិនមកចឹងវាដល់ចង់ពាក់កណ្តាល ។

វណ្ណៈ បាទ ។

ឡាំង ៖ វាដកយកទៅសម្រាប់ដាក់ក្នុងឃ្លាំងរបស់វា វាដឹកយកមកឲ្យយើងផ្សេង ។

វណ្ណៈ ចឹងដូចថាខាងចិនឲ្យសម្ភារអីថៃវាយកពាក់កណ្តាល?

ឡាំង ៖ បាទ!ដកយកពាក់ចឹងទៅណាស់ ។

វណ្ណៈ ដកពាក់កណ្តាលឬក៏ដកតែ៣០ភាគរយ?

ឡាំង ៖ ខ្ទង់៣០ភាគរយ ។

វណ្ណៈ ពាក់កណ្តាលឬមួយ៣០ភាគរយ?

ឡាំង៖ អត់ទេ ប្រហែលជា៣០ភាគរយ់

វណ្ណៈ ចឹងបានជាកំលាំងខ្មែរក្រហមចាញ់ខាងថៃមិនធ្វើអីទេ រហូតទៅជួបទាហានថៃចឹងក៏មិនអីដែរមែនទេ?

ឡាំង ៖ វាធ្វើបាបដែលបើយើងទៅមិនបានជាក្រុមជាកង បើដាច់ដោយឡែកយ៉ាប់ដែរ វាធ្វើបាបដែរវាធ្វើបាបយើងដឹថាអត់មានពីណាគ្រប់គ្រងណាស់ ។ ។

វណ្ណៈ ចឹងពូកាលជំនាន់៧៩-៨១-៨២ កាលហ្នឹងដើមឈើមានកាប់លក់ឲ្យថៃដែលឬក៏មិនទាន់កាប់លក់ឲ្យថៃទេ?

ឡាំង ៖ កាលជំនាន់ហ្នឹងមិនទាន់ទេ ។

វណ្ណៈ ចឹងជំនាន់ណាបានកាប់?

ឡាំង ៖ ជំនាន់ក្រោយៗមកទៀត បានកាប់កាលនោះជិតផ្តាច់ខ្លួនដែលហ្នឹងណាស់ ។

វណ្ណៈ ចឹងពូមានចាំឆ្នាំដែលផ្តាច់ខ្លួនចូលជាមួយខាងរដ្ឋាភិបាលទេ?

ឡាំង ៖ ខ្ញុំមិនបានចាំឆ្នាំដែរ កាលហ្នឹងខ្ញុំវីវក់រឿងដាច់ជើងផងខ្ញុំមិនដឹងជាប៉ុន្មានអីប៉ុន្មានទេ ។

វណ្ណៈ បាទ ។

ឡាំង ៖ កាលខ្ញុំដាច់ជើងខ្ញុំទៅដល់ចាន់ប្រទេសថៃ ពេទ្យពិសេសៗគេខ្ញុំដេកនៅហ្នឹងអស់ប៉ុន្មានលាននោះ ។

វណ្ណៈ ចឹងខាងកំលាំងខ្មែរក្រហមដាច់ជើងច្រើនគ្នាដែរ?

ឡាំង ៖ ច្រើនគ្នានាក់ណាស់ ។

វណ្ណៈ តាមពូគិតប្រហែលជាប៉ុន្មាននាក់ដែរ?

ឡាំង ៖ ប្រហែលជា២០០ទៅ៣០០នាក់ដឹង ។

វណ្ណៈ បើគិតមកដល់ឥឡូវ?

ឡាំង៖ បាទ ។

វណ្ណៈ ចឹងអ្នកស្លាប់ផ្សេងយើងមិនបាច់គិតទេ យើងគិតតែអ្នកពិការ?

ឡាំង ៖ បាទ ។

វណ្ណៈ ចឹងអ្នកទាំងហ្នឹងដាច់ជើងដោយសាសគ្រាប់ឬមួយដាច់ជើងនៅពេលយើងកាប់រានយកដីថែមទៀត?

ឡាំង ៖ អាហ្នឹងម្យ៉ាងមកពីយើងទន្ទ្រានខ្លះ
ទន្ទ្រានយកដីខ្លះដូចថាចង់បានចេកហូបអីចឹងទៅកាលនោះជំនាន់តាមជួរព្រំដែនហ្នឹងដីខាងនោះគេមកនៅចាស់ហ្នឹងមានចេកអីចឹងខ្លះឃើញចេកទុំចូលទៅកាបឹងទៅដាច់ជើងក៏មានដូចជាបងខ្ញុំនៅកន្ទែងក្បាលស្ពាន ។

វណ្ណៈ បាទ ។

ឡាំង ៖ គាត់ចូលទៅ ឃើញគេចូលទៅបានគាត់ចូលទៅហ្នឹងគេទៅគាត់ចូលទៅដាច់ជើង ។

វណ្ណៈ បាទ ។

ឡាំង៖ ចុះគាត់ឃើញចេកទុំឡើងវែងៗនោះ ។

វណ្ណៈ ចឹងកាលហ្នឹងគេថាដើមឈើជិតប៉ុនពាងចង់មួយអោបៗអីចឹងណាស់ តាមពូគិតជិតសមាហរណ៍កម្មហើយបានអស់ឈើហ្នឹង?

ឡាំង ៖ បាទ ។

វណ្ណៈ ចឹងឈើទាំងអស់ហ្នឹងអ្នកណាកាប់?

ឡាំង : និយាយរួមចែកគ្នាកាប់ ។

វណ្ណៈ កាប់យកទៅធ្វើអី?

ឡាំង : កាប់យកទៅលក់ឲ្យថៃដើម្បីដោះស្រាយជីវភាព ។

វណ្ណៈ ដោះស្រាយជីវភាពកងទ័ព?

ឡាំង : បាទ ។

វណ្ណៈ ខ្ទង់៩០ដាង?

ឡាំងៈ បាទ ។

វណ្ណៈ ចឹងដើម្បីដោះដូរជាមួយថៃយកសម្ភារ?

ឡាំង : បាទ!យកដូចជាស្ពឺៗស៊ីលិចកើតហ្នឹងណាស់ ។

វណ្ណៈ ព្រោះកាលហ្នឹងចិនជិតផ្តាច់ជំនួយហើយ?

ឡាំងៈ បាទ ។

វណ្ណៈ ឆ្នាំ៩០ផ្តាច់ហើយ?

ឡាំង : បាទ!ផ្តាច់ហើយព្រោះកាលនោះម៉ាជំនាន់នោះ យួនវាវៃបើកទ្រុងទ្រាយធំហើយវាមិនបានសម្រេចវាសុខចិត្តដកចេញពីប្រទេសកម្ពុជាហ្នឹងទៅ ដកទៅវានៅខ្មែរវៃជាមួយខ្មែរបើចឹងចិនឈប់ជំនួយឲ្យយើងដែលព្រោះយើងខ្មែរវៃខ្មែរ ។

វណ្ណៈ ចឹង?

ឡាំង : បាទ!ចិនសំខាន់ទី១ជាមួយយួននោះ ។

វណ្ណៈ ចឹង?

ឡាំង : ដើម្បីថាយួនចង់លេបត្របាក់ប្រទេសខ្មែរណាស់ ដល់ចឹងគេជំនួយមកដើម្បីតតាំងជាមួយយួនហ្នឹង ។

វណ្ណៈ ចឹងពេលយួនចេញ?

ឡាំង : ពេលយួនចេញគេផ្តាច់ជំនួយដែរ ព្រោះគេថាខ្មែរនិងខ្មែរមិនត្រូវច្បាំងគ្នាទេ ។

វណ្ណៈ ចឹងចិនឈប់ជំនួយនៅឆ្នាំណាពូមានចាំដែរ?

ឡាំង : ខ្ញុំមិនបានចាំដែរ ។

វណ្ណៈ ចឹងតាមពូគិតមើលយួនដកអស់ពីស្រុកខ្មែរនៅឆ្នាំណា?

ឡាំងៈ បាទ ។

វណ្ណៈ ឆ្នាំ១៩៨៧ចឹងចាប់ពីពេលហ្នឹងមក?

ឡាំង: ចាប់ពីពេលហ្នឹងមកគេអត់មានជំនួយទៀតទេ ព្រោះវា ។

វណ្ណៈ ចឹងកាលហ្នឹងខាងខ្មែរក្រហមដោះស្រាយដោយខ្លួនឯង?

ឡាំង : ដោះស្រាយដោយខ្លួនឯង ។

វណ្ណៈ ចឹងនៅតំបន់ខ្លះជីកវែលក់ទៅ នៅកន្លែងតំបន់ខ្លះកាប់ឈើលក់ទៅ?

ឡាំង : បាទ! ម្យ៉ាងទី១ យើងចេះតែច្នៃលិចកើតទៅណាស់ ។

វណ្ណៈ បាទ ។

ឡាំង: ដូចជាយើងជីកត្បូងជាជាអីយកមកធ្វើជាក់ធ្វើមីនគោនអីចឹងណាស់ ។

វណ្ណៈ បាទ ។

ឡាំង: អាហ្នឹងចាប់ផ្តើមដំណើរការដោយខ្លួនឯងហើយ ដើម្បីដោះស្រាយបានមួយរយៈហ្នឹងបានកាល នោះយើងមិនផ្តាច់ខ្លួន ។

វណ្ណៈ បាទ ។

ឡាំង: ចឹងសុំផ្តាច់ខ្លួនបណ្តោយទៅព្រោះខ្មែរនិងខ្មែរ យើងទៅច្បាំងយកអីទៀតទេ ។

វណ្ណៈ បាទ ។

ឡាំង : ដល់ចឹងទៅសុំបញ្ចប់ត្រឹមហ្នឹងទៅ មេធំៗខាងហ្នឹងទៅជួបមេធំៗខាងនោះដែលទៅណាស់ ។

វណ្ណៈ ចឹងទៅជួបខាងសម្តេចហ៊ុន សែន?

ឡាំង : បាទ! ទៅជួបសម្តេចហ៊ុន សែន ហើយសម្តេចហ៊ុន សែនបានបញ្ជាមកៗហើយគាត់ចុះមកដល់ តំបន់ម៉ាឡៃនេះផ្ទាល់ដែលទៅ ។

វណ្ណៈ ចុះមកនៅឆ្នាំណា?

ឡាំង : ខ្ញុំមិនចាំឆ្នាំដែរ ។

វណ្ណៈ ចឹងសម្តេចហ៊ុន សែនចុះមកដល់ម៉ាឡៃហ្នឹងដែរ?

ឡាំង : មកដល់ម៉ាឡៃហ្នឹងដែរសម្តេចមកម៉ាឡៃហ្នឹងប៉ុន្មានដងឯណោះ ។

វណ្ណៈ នៅពេលផ្តាច់ខ្លួនហើយ?

ឡាំង : បាទ ។

វណ្ណៈ ចឹងសម្តេចហ៊ុន សែនមកដល់ម៉ាឡៃហ្នឹងប៉ុន្មានដង?

ឡាំង : ពីរដង កាលហ្នឹង ។

វណ្ណៈ ចឹងពូយល់យ៉ាងម៉េចដែរ ដែលខាងខ្មែរក្រហមព្រមផ្តាច់ខ្លួនដើម្បីសម្របសម្រួលជាមួយរដ្ឋាភិបាលពូមានគំនិតយ៉ាងម៉េច ដែរ?

ឡាំង ៖ នឹកឃើញម្យ៉ាងល្អ ។

វណ្ណៈ   ល្អ?

ឡាំង ៖ បាទ ។

វណ្ណៈ   ល្អយ៉ាងម៉េច?

ឡាំង ៖ ល្អម្យ៉ាងវាអត់មានលំបាកដាច់ដៃដាច់ជើងខូចមានគ្រោះថ្នាក់អី  យើងបានធ្វើដូវបានស្រួលហើយ យើងមិនបានទៅមុខយើងនៅជាមួយប្រពន្ធកូនចឹងទៅវាស្រួលវាល្អ ។

វណ្ណៈ   ចឹងកាលខ្លួនពូផ្ទាល់នៅកំពង់ធ្វើសង្គ្រាមមានការភ័យខ្លាចទេ?

ឡាំង ៖ ភ័យខ្លាចដែរ ។

វណ្ណៈ   ខ្លាចដែលជាកាតព្វកិច្ចយ៉ាងម៉េច?

ឡាំង ៖ កាលហ្នឹងដូចជាត្រូវទឹសបើគេដាក់ទឹសមកយើងមិនទៅមានតែប្រឆាំង ។

វណ្ណៈ   ចឹងនៅពេលមានសង្គ្រាមនិងគ្មានសង្គ្រាមចិត្តពូស្រឡាញ់មួយណា?

ឡាំង ៖ ស្រឡាញ់អត់មានសង្គ្រាមទេ  អត់មានសង្គ្រាមស្រួលជាង  ។

វណ្ណៈ   ចឹងកាលពូធ្វើសង្គ្រាមច្បាំងជាមួយយួននិងជាមួយទាហានខ្មែរខាងក្នុង  កាលហ្នឹងពូអត់មានព្រួយបារម្ភណ៍ទេមានហូបចុកគ្រប់គ្រាន់?

ឡាំង ៖ បាទ ។

វណ្ណៈ   ចឹងមកដល់ឥឡូវពូមានសិទ្ធសេរីភាពបរបូរចឹងហើយត្រឡប់ទៅវិញពូគិតថា    បច្ចុប្បន្ននេះស្រួលជាងឬកាលមុនស្រួលជាងបើគិតទៅ  ?

ឡាំង ៖ គិតទៅគិតមកធម្មតាកាលជំនាន់នោះថាភ័យខ្លាចណាស់ ។

វណ្ណៈ   បាទ ។

ឡាំង ៖ មកដល់ជំនាន់នេះវាពិបាកដែរ    តែយើងបានជួបជុំគ្រួសារហើយយើងដោះស្រាយបានសម្រេចចង់ធ្វើអីយើងធ្វើបានចឹងទៅណាស់ ។

វណ្ណៈ   បាទ ។

ឡាំង៖  អត់មានថាអេងធ្វើកន្ទែងអញអត់បានទេ  មិនមែនទេយើងចង់ធ្វើអីយើងធ្វើបានយើង  ចង់ទៅចំការអីបានទាំងអស់ ។

វណ្ណៈ   យើងចង់ទៅចំការយើងចង់ដើរលេងបាន?

ឡាំង៖    យើងចង់ដើរលេងដល់ណាក៏បានយើងចង់ដើររកស៊ីនៅណាក៏បានអត់មានពីណាហាមឃាត់ទេម៉ាជំនាន់នោះយើងចង់ទៅណាទាល់តែមានច្បាប់ទំលាប់ ។

វណ្ណៈ   ទាល់មានច្បាប់ទំលាប់ពូណឺស?

ឡាំង: បាទ ។

វណ្ណៈ ចឹងបើប្រៀបធៀបទៅឥឡូវស្រួលជាង?

ឡាំង : ឥឡូវស្រួលជាង ។

វណ្ណៈ យើងរកស៊ីបានប៉ុន្មានយើងបានប៉ុណ្ណឹង?

ឡាំង : បាទ ។

វណ្ណៈ អត់មានពីណាមកហាមឃាត់យើងទេ?

ឡាំង : អត់មានពីណាហាមឃាត់ទេ តែពិបាកទីមួយវាស្រួលម្យ៉ាងទី១វាពិបាកអារឿងពួកគេរកស៊ីជក់ម៉ា អីហ្នឹងគិតរឿងហ្នឹងម្យ៉ាងដែរ ។

វណ្ណៈ ចឹងឥឡូវខ្វល់រឿងជក់ម៉ា?

ឡាំង : បាទ ។

វណ្ណៈ ចឹងកាលជំនាន់ខ្មែរក្រហមមិនទាន់ផ្តាច់ខ្លួនគ្មានចោរឬមួយមានចោរដែរ?

ឡាំង : អត់មានទេ ។

វណ្ណៈ ឥឡូវមានចោរទេ?

ឡាំង : ឥឡូវមានចោរហើយមានពួកអ្នកជក់ម៉ាហើយធ្វើចោរតែម្តង ។

វណ្ណៈ ចឹងលោកអ៊ំ ខៀវ សំផន លោកអ៊ំអៀង សារីនិងលោកអ៊ំប៉ុល ពតមានដែលមកជួបប្រជាជន ដោយផ្ទាល់ទេ កាលឆ្នាំ១៩៧៩-៨១-៨២អីហ្នឹងនៅតំបន់ហ្នឹងមានមកសន្និបាតឬមកធ្វើអី?

ឡាំង : មានមកដែរ ។

វណ្ណៈ គាត់មកធ្វើអី?

ឡាំង : គាត់មកចង់ជួបអ្នកធំៗនៅកន្លែងហ្នឹងទៅណាស់ ។

វណ្ណៈ ចង់ជួបជាមួយកងទ័ពទេ?

ឡាំង : ជាមួយកងទ័ពគាត់មិនសូវមកទេ គាត់មានវិបត្តិច្រើន កាលនោះគាត់មកម្តងដែរ ។

វណ្ណៈ គាត់មកគាត់ប្រាប់យើងថាយ៉ាងម៉េចខ្លះ?

ឡាំង : គាត់ប្រាប់យើងលិចកើតទៅគាត់ទៅវិញទៅព្រោះគាត់មានវិបត្តិ ។

វណ្ណៈ គាត់ប្រាប់ថាយ៉ាងម៉េចខ្លះ?

ឡាំង : គាត់ប្រាប់ឲ្យយើងតស៊ូទៅ ។

វណ្ណៈ តស៊ូដើម្បីអី?

ឡាំង: តស៊ូដើម្បីដេញយួនចេញពីស្រុក គាត់និយាយចឹងតែម្តង ។

វណ្ណៈ ចឹងថាក្រោយមកគាត់មានវិបត្តិអីដែរ?

ឡាំង៖ គាត់កាលនោះមិនសូវស្រួលផង ។

វណ្ណៈ កាលហ្នឹងគាត់មិនសូវស្រួលយ៉ាងម៉េច?

ឡាំង ៖ កាលនោះជំងឺគាត់ដូចជាខ្សោយណាស់ គាត់នៅយូរមិនបានខ្សោយគាត់ទៅគាត់មិនបាននៅយូរ គាត់មកនៅហ្នឹងកាលហ្នឹងសម្តេចសីហនុក៏មកនៅកន្លែងហ្នឹង ។

វណ្ណៈ ចឹងសម្តេចសីហនុយាងមកកាលឆ្នាំណា?

ឡាំង ៖ ខ្ញុំមិនដឹងជាឆ្នាំប៉ុន្មានទេខ្ញុំចាំមិនបានដែរ ។

វណ្ណៈ បែកឆ្នាំ៧៩ហើយ?

ឡាំង ៖ ហ្នឹងហើយបែក៧៩ហើយ កាលគស៊ូខាំងហ្នឹងតឹងតែងហ្នឹង កាលគាត់មកមិនឲ្យពីណាដឹងទេ សព្វថ្ងៃគេហៅកន្លែងសារតាំងសព្វថ្ងៃហ្នឹង ។

វណ្ណៈ ចឹងកាលគាត់មកតំបន់ខ្មែរក្រហម?

ឡាំង ៖ បាទ! កាលនោះគាត់មកសំណាក់កន្លែងហ្នឹង ហើយកាលនោះមានយួនបុកចូលមក ពួកយើងខាងក្នុងមកដែរកាលហ្នឹងខ្ញុំឮតែគេថាទេ ។

វណ្ណៈ បាទ ។

ឡាំង ៖ គេថាមករើកន្លែងផ្ទះសំណាក់របស់គាត់មិនបានផង ចុកពោះសាប់ខ្លះ ។

វណ្ណៈ កន្លែងសារតាំងសព្វថ្ងៃហ្នឹង?

ឡាំង ៖ បាទ!កន្លែងសារតាំងហ្នឹង ។

វណ្ណៈ កាលហ្នឹងគាត់មកជួលសារជាមួយថៃឬជាមួយខ្មែរក្រហម?

ឡាំង ៖ គាត់ចូលពីថៃមកចូលមកហ្នឹងតែម្តង ។

វណ្ណៈ មានថៃអីចូលមកទេ?

ឡាំង ៖ មានថៃចូលមកក្នុងហ្នឹង ។

វណ្ណៈ គាត់ចូលមកប៉ុន្មានដង?

ឡាំង ៖ កាលហ្នឹងគាត់ចូលមកខ្ញុំឃើញតែម្តងទេ ។

វណ្ណៈ គាត់មកមាននិយាយអ្វីជាមួយកងទ័ពខ្មែរក្រហមទេ?

ឡាំង ៖ គាត់ចូលមកអត់មាននិយាយអីប៉ុន្មានទេ កាលនោះគាត់មកមានសម្ភាសន៍ដែរ តែខ្ញុំមិនបានដឹងថាសម្ភាសន៍ជាមួយអ្នកណាទេ គាត់មកដល់ហ្នឹងហើយគាត់ជិះដំរីទៅខាងនោះ ។

វណ្ណៈ ចឹងកាលហ្នឹងគាត់អត់មានជិះឡានទេ?

ឡាំង ៖ អត់ទេ គាត់ជិះតែដំរីទេ ។

វណ្ណៈ ចឹងកាលសម្តេចយាងមកហ្នឹងជិះដំរីដែរ?

ឡាំង ៖ បាទ!ជិះដំរី កាលនោះខ្ញុំមិនស្គាល់ឯណា គាត់ស្លៀកខោអាវធម្មតា ខោអាវចិន ។

វណ្ណៈ ចឹងចូលពីខាងថៃមក?

ឡាំង ៖ បាទ!កន្លែងក្បាលស្ពាន ។

វណ្ណៈ កន្លែងក្បាលស្ពាន?

ឡាំង៖ បាទ!កន្លែងក្បាលស្ពាន ស្ពានប្រកហ្នឹង ។

វណ្ណៈ ចឹងចូលមកដល់ក្នុងនេះតែម្តង?

ឡាំង ៖ ចូលមកដល់កន្លែងសារតាំងហ្នឹង ដល់ហើយគាត់ថាចង់ទៅលេងកូនចៅគាត់ទៅខាងនោះ ចឹងគេដង្ហែរពីនេះទៅ ទៅគីឡូ១២ គីឡូ១៣ ចក្រីចឹងទៅណាស់ គាត់ជិះដំរីជាមួយភ្ញៀវ ។

វណ្ណៈ កាលហ្នឹងមានដំរីច្រើនទេ?

ឡាំង ៖ មានដំរីបួន ។

វណ្ណៈ ចឹងកាលហ្នឹងមានចិនមកទៀត?

ឡាំង ៖ មានចិន ។

វណ្ណៈ មានភ្ញៀវចិនថៃ?

ឡាំង៖ មានភ្ញៀវចិនថៃនិងពួកនេះគេមកដែរ គេហៅពួកបារាំងក៏មកដែរ ។

វណ្ណៈ ចឹងពូឃើញមានអ្នកកាសែតទេ?

ឡាំង ៖ មានអ្នកកាសែត ។

វណ្ណៈ មានច្រើនទេ?

ឡាំង ៖ មានប្រហែលជិត២០នាក់ហ្នឹង ។

វណ្ណៈ ចឹងអ្នកកាសែតជិះអីទៅ?

ឡាំង ៖ អ្នកកាសែតដើរធម្មតា ។

វណ្ណៈ ចឹងអ្នកធំទេបានជិះដំរី?

ឡាំង៖ អ្នកធំហើយនិងទូតគេហ្នឹងហើយអ្នកកាសែតដើរធម្មតា ដើរជាមួយពួកខ្ញុំដែលហ្នឹង ។

វណ្ណៈ ចឹងអ្នកកាសែតដើរធម្មតាទេ?

ឡាំង៖ កាលជំនាន់ហ្នឹងគេដើរតាំងពីហ្នឹងទៅខ្ទះខ្ទិលទៅអ្នកកាសែតដើរឆ្ងាយយើងគេហៅអន្ទង់សំណរហ្នឹងហ្នឹងហើយទៅដល់ហ្នឹងឯង ។

វណ្ណៈ ចឹងដើរចូលកាលហ្នឹងអត់មានជួបប្រទះជាមួយទាហានយួនវៃចូលឬមួយទាហាខាងក្នុងវៃមកទេ?

ឡាំង ៖ អត់ដែលផង ។

វណ្ណៈ នៅពេលសម្តេចសីហនុយាងចូលមក?

ឡាំង ៖ អត់មានឃើញប៉ះអីផង ។

វណ្ណៈ ចឹងដូចជាគេរៀបរាងទុក?

ឡាំងៈ ហ្នឹងហើយដូចស្រួលអត់មានពិបាកទេ គាត់ជិះដំរីមើលតាមតែផ្លូវហ្នឹងទៅចឹងទៅ ។

វណ្ណៈ ចឹងពូដឹងថាគាត់មកនៅក្នុងព្រៃហ្នឹងប្រហែលជាប៉ុន្មានថ្ងៃគាត់ត្រឡប់ទៅវិញ?

ឡាំង ៖ កាលហ្នឹងប្រហែលជាពីរបីថ្ងៃដែរដឹង ។

វណ្ណៈ ចឹងគាត់សម្រាកនៅក្នុងព្រៃដែរ?

ឡាំង ៖ បាទ!គាត់សម្រាកនៅក្នុងព្រៃដែរ កន្លែងគាត់ដេកហ្នឹងមិនធម្មតាទេគេធ្វើតប់តែងស្អាតណាស់ សូម្បីបង្គន់ដាក់ធ្វើនៅក្នុងព្រៃក៏ធ្វើឲ្យស្អាតដែរ ។

វណ្ណៈ ចឹងមានបង្គន់នៅក្នុងព្រៃ?

ឡាំង ៖ បាទ!មានបង្គន់ដាក់ឲ្យស្អាតណាស់ ។

វណ្ណៈ ចឹងចាប់ផ្ដើមភ្លាមៗ?

ឡាំង ៖ ចាប់ផ្ដើមថាគំរោងគាត់យាងមកគេរៀបចំឲ្យភ្លាមៗ ។

វណ្ណៈ ចឹងកាលហ្នឹងពីណាជាអ្នករៀបចំឲ្យអ្នកមុខអ្នកការ?

ឡាំង ៖ អ្នកមុខអ្នកការជាមេធំៗហ្នឹង កាលជំនាន់ហ្នឹងឈ្មោះកននៅហ្នឹង ហើយខាងត្បូងគេហៅ៣២ ។

វណ្ណៈ បាទ!ចឹងកាលហ្នឹងតា ប៉ុល ពត អៀង សារីគាត់បានជួបសម្ដេចទេ?

ឡាំង ៖ ជួប ។

វណ្ណៈ ចឹងកាលហ្នឹងតា ខៀវ សំផន តា អៀង សារីសម្ដេចមកសារតាំងមានមកទទួល?

ឡាំង ៖ មកទទួលជិះដំរីជាមួយគ្នាហ្នឹងឯង តាំងភ្ញៀវចិនទាំងអស់ កូនចៅដើរទៅ អ្នកកាសែតដើរទៅ ។

វណ្ណៈ ចឹងប៉ុល ពត?

ឡាំង ៖ កាលហ្នឹងប៉ុល ពត អត់ឃើញមក មកតែអឹ ។

វណ្ណៈ ចឹងមកតែអឹអៀង សារីនិង ខៀវ សំផន?

ឡាំង ៖ បាទ ។

វណ្ណៈ ចឹងតាម៉ុក?

ឡាំង ៖ តាម៉ុកអីអត់ឃើញមានផង ។

វណ្ណៈ ចឹងនៅពេលក្រោយមកទៀតសភាពការណ៍នៅម៉ាឡៃហ្នឹងយ៉ាងម៉េចដែរ?

ឡាំង ៖ ក្រោយៗមកទៀតជំនាន់ហ្នឹងគេវៃពួកយួនចូលមកវៃទ្រង់ទ្រាយធំណាស់ វៃយកម៉ាដូរព្រំដែនទាំងអស់ ទៅសំណាក់ព្រំដែនថៃយូរដែលហ្នឹងជិតមួយឆ្នាំដែរ ។

វណ្ណៈ បាទ ។

ឡាំង ៖ ហើយដល់ពេលនេះវិចូលមកវិញ ពួកយួនវែងណើមយកតាមឃុំងនេះអស់ហើយណាស់ ។

វណ្ណៈ  បាទ ។

ឡាំង ៖ ដូចជាគ្រាប់រំសេវអីឃុំងសម្ភារអីហ្នឹងយកអស់ហើយ កាំភ្លើងអូសចូលដីថៃ ថៃអឹមអូសយកទុកបាត់ហើយ ដល់ចឹងទៅវិចុះឡើងដណើមបានមកវិញ ។

វណ្ណៈ  បាទ ។

ឡាំង ៖ បានមកវិញបាននៅដល់សព្វថ្ងៃហ្នឹង ។

វណ្ណៈ  ចឹងនៅពេលវិជាមួយយួនពូមានដឹងថាយួនស្លាប់ច្រើនទេ?

ឡាំង ៖ យួនស្លាប់ច្រើន ។

វណ្ណៈ  ស្លាប់ច្រើនចឹងយួនស្រីៗទេ?

ឡាំង ៖ ដូចជាអត់មានស្រីផង មានតែប្រុសៗយួនវាសាហាវណាស់ ។

វណ្ណៈ  សាហាវយ៉ាងម៉េចទៅ?

ឡាំង ៖ សាហាវទី១វាអានកំលាំងវាច្រើនពេលបាញ់វាហោកញ្ញៀវហើយអាសត្វហ្នឹង វាហៅឡើងវាស្រែកឡើងជាពិសេសដឹងដាច់ជើងមួយពីរចឹងវាស្រែរូកវាស់ៗគ្នាវាហ្នឹង ។

វណ្ណៈ  អ!ដាច់ជើងគ្នាវាហ្នឹងវាស្រែកឡើង?

ឡាំងៈ  យើងធម្មតាកំលាំងយើងតិចជាងវា ចែកជាក្រុមៗវាមកម្តងផ្លូវព្រៃឡើងណែនម៉េះឡើងក្រហ៊ូដិះកង់កើត ហ្នឹងគ្រាន់តែកំលាំងវា ។

វណ្ណៈ  កាលហ្នឹងមានរថក្រោះអីទេពូ?

ឡាំង ៖ កាលនោះថ្មើរជើង ។

វណ្ណៈ ចឹងអត់មានរថក្រោះទេ?

ឡាំងៈ  រថក្រោះវាចូលមកតាមក្រោយ ចូលមកមិនរួចព្រៃ វាផ្លោងមកពីចម្ងាយមក ។

វណ្ណៈ  ចឹងរត់ក្រោះចូលមកមិនរួចទេ?

ឡាំង ៖ បាទ ។

វណ្ណៈ  ចឹងកំលាំងវាលូនចូលមក?

ឡាំងៈ  បាទ!តែយួនវាខ្លាំងទី១ម្យ៉ាងវាអត់មានដូចខ្មែរក្រហមនោះវាមិនហ៊ានដូចទាហានខ្មែរយើងទេ វាមកត្រៀមហើយស្រេចដូចថាខ្លួនខ្ញុំមួយចឹង វាត្រូវទុកស្បោងមួយសម្រាប់ដាក់ខ្លួនវាសម្រាប់ខ្ចប់ខ្លួនថាទៅវិញ ។

វណ្ណៈ  ចឹង?

ឡាំង ៖ បាទ! ដូចខ្ញុំមួយចឹងខ្ញុំស្ពាយស្បោងសម្រាប់ដាក់នៅពេលស្លាប់ទៅហើយស្បោងខ្ញុំមានស្រេច ។

វណ្ណៈ ចឹងខាងខ្មែរក្រហមមានធ្វើចឹងទេ?

ឡាំង ៖ អត់មានទេ ។

វណ្ណៈ ចឹងយួនបើវាចាប់មានសម្ភារវា?

ឡាំង ៖ យួនបើវាចាប់ វាមានស្បោងរំខ្លួនវានិងថ្នាំហើយស្រេច បើចាប់វះពោះចេញហើយដាក់ថ្នាំចូលទៅរុំយកទៅស្រុកវាតែម្តង ។

វណ្ណៈ ចឹងវាចាប់អត់កប់ចោលនៅហ្នឹងទេ?

ឡាំង ៖ អត់មានកប់ចោលហ្នឹងទេ ទោះប៉ុន្មានថ្ងៃវាឡើងយកមកទាល់តែបាន អត់មានចោលខ្មោចផ្តេះផ្តាស់ទេ វាវះពោះតែម្តង ។

វណ្ណៈ ចឹងពូយ៉ាងម៉េចបានដាដឹងច្បាស់យ៉ាងនេះ?

ឡាំង ៖ ខ្ញុំដឹងច្បាស់ សូម្បីអំពូលថ្នាំវាមិនទុករហេករហូតឲ្យដឹងផង វាដឹកកប់ទៀតនោះ ។

វណ្ណៈ វាយកទៅស្រុកវាវិញ?

ឡាំង៖ មិនដឹងវាខ្លាចបែកការណ៍ក៏មិនដឹង ព្រោះវាខ្លាចយើងប្រើរឿងរបស់វាដឹង ។

វណ្ណៈ ចឹងមានស្បោងប្រកខ្លួនវា?

ឡាំង ៖ និយាយរួមមានមួយចប់របស់វាតែម្តង មានស្បោងសម្រាប់ដាក់ទឹកវាដឹក ហើយថ្នាំពេទ្យមានមួយកំភ្លេរបស់វាតែម្តង ហើយថ្នាំពេទ្យមានមួយកំភ្លេតែម្តង ។

វណ្ណៈ ចឹងនៅពេលចាប់បានម្នាក់អីមើលឃើញមានទាំងអស់?

ឡាំង ៖ ហ្នឹងហើយមើលឃើញមានទាំងអស់ នៅពេលវាចាប់អាខ្វះរត់ចោលវ៉ាឡូវាបានដឹងថាមាននៅក្នុងហ្នឹងមួយចប់ មានថ្នាំនៅហ្នឹងស្រេច អ្នកចាប់បានខ្វះមិនដឹងយកទៅដាក់ទឹក ខ្ញុំថាអាហ្នឹងមិនមែនសម្រាប់ដាក់ទឹកទេ សម្រាប់ដាក់ខ្លួនវា ។

វណ្ណៈ ស្បោងវាធំៗ?

ឡាំង ៖ និយាយរួមវែងល្មមសម្រាប់ប្រកខ្លួនឯង បើខ្ញុំចេះមើលអក្សរវាដឹងមើលទៅ តែខ្ញុំមិនចេះ ។

វណ្ណៈ បាទ ។

ឡាំង ៖ វាដាក់អក្សរនៅហ្នឹងស្រេចហើយហ្នឹង ស្បោងសម្រាប់ដាក់ខ្លួនវាហ្នឹង ។

វណ្ណៈ ចឹងធ្វើសង្គ្រាមពិបាកណាស់?

ឡាំង ៖ ពិបាកណាស់ គ្មានអីពិបាកជាងសង្គ្រាមទេ ។

វណ្ណៈ ចឹងពូដាច់ដើងហ្នឹងនៅពេលណាពេលឡើងវៃឬយ៉ាងម៉េច?

ឡាំង ៖ ពេលកាលនោះអត់បានឡើងវៃទេ កាលនោះឡើងទៅដាក់មីនស្កាត់កុំឲ្យកំលាំងវាចូលមកចឹងអានេះកាលជិតនាន់យើងខ្មែរនិងខ្មែរទេ ។

វណ្ណៈ   ចឹងពូដាច់ជើងនៅឆ្នាំណាឆ្នាំ៩០ ជាង៩០ ប៉ុន្មានពូ?

ឡាំង  : ឆ្នាំ៩១ អីហ្នឹង ។

វណ្ណៈ   ចឹងកាលហ្នឹងមិនទាន់មានអ៊ុន  គាត់មកទេ?

ឡាំង  : អ៊ុន  គាត់មកទៅវិញហើយហ្នឹង ។

វណ្ណៈ   ចឹងមានតែឆ្នាំ៩០ ជាងជិតផ្តាច់ខ្លួន?

ឡាំង  : បាទ!ជិតផ្តាច់ខ្លួនហើយហ្នឹង ។

វណ្ណៈ   ចឹងដាច់ជើងហ្នឹងបានមួយឆ្នាំហើយនៅផ្តាច់ខ្លួន?

ឡាំង  : អត់ទេ  កាលហ្នឹងបានមួយខែហ្នឹង  មិនដល់មួយខែផង ។

វណ្ណៈ   ចឹងឆ្នាំ៩៦ ?

ឡាំង  : បាទ!  កាលហ្នឹងមានវ៉ៃខ្លាំងលិចកើតហ្នឹងណាស់ ។

វណ្ណៈ   ចឹងប្រហែលជាខែប៉ុន្មានទៅដាច់ជើង៩៦ ? '

ឡាំង:   មិនចាំទេ ។

វណ្ណៈ   ចឹងនៅពេលដាច់ជើងហ្នឹងពូទៅព្យាបាលនៅណា?

ឡាំង  : ដូចខ្ញុំថាចឹងទៅព្យាបាលនៅថៃ ។

វណ្ណៈ   ចឹងនៅថៃជាមកវិញ?

ឡាំង  : កាលហ្នឹងប្រហែលជាមួយអាទិត្យ ។

វណ្ណៈ   ចឹងតែមួយអាទិត្យទេលឿនដែរ?

ឡាំង  : បាទ!តែមួយអាទិត្យទេ   ម្យ៉ាងព្យាបាលនៅថៃហ្នឹងអត់មានចាំលាងដូចខ្មែរយើងទេ   វាទៅធ្វើឲ្យស្អាតហើយទុកចោរតែម្តង ។

វណ្ណៈ   កាត់ចោលតែម្តង?

ឡាំង:   កាត់វាលាងស្អាតចឹងទៅវាបិតចោលតែម្តងវាដាក់ថ្នាំបញ្ចូកមកអទ់មានធុករុកដូចខ្មែរយើងទេណាហ្នឹងហើយវ៉ៃផ្សះពីក្នុងហ្នឹងមកតែម្តងអត់មានលាងមានដូតទេ   អ្នកចង់ដូតហ្នឹងទាល់អ្នកដុកទ័រធំវាមកបើកមើលវាប្រចាំបាច់មុខយើងហ្នឹងសួរយើងថាឈឺអត់   បើយើងថាមិនសូវឈឺវាថាជាហើយ ។

វណ្ណៈ   បាទ ។

ឡាំង  : អត់មានកាលជំនាន់យើងខ្មែរក្រហមកាលនោះកន្លែងណាមុខរបួសគេរុកហើយណាស់   ដើម្បីឲ្យអស់ជាតិខ្ទុះមិនចឹង ។

វណ្ណៈ   ចឹងពេលរុកហ្នឹងមានចាក់ថ្នាំស្ពឹកទេ?

ឡាំង ៖ អត់មានចាក់ទេ ខ្មែរយើងហ្នឹងណាស់ ។

វណ្ណៈ   ចឹងមិនឈឺរាប់ហើយ?

ឡាំង ៖ ឈឺស្រែកទៅ   ធម្មតាដើងយើងដាច់ទាំងមូលមិនមានសរសៃរួមនៅហ្នឹងទាំងអស់   កន្លែងណាក៏សរសៃរប្រាសាទដែរ ។

វណ្ណៈ   ចឹងនៅថៃកាត់តែម្តងអត់មានលាងទេ?

ឡាំង ៖ កាត់តែម្តងអត់មានលាងទេ វាប្រើថ្នាំផ្សះហ្នឹងបណ្តោយអត់មានលាងទៀតទេគ្រាន់តែវាដាក់ទុយទុយយោចំកណ្តាលហ្នឹងមួយឲ្យវាហូរទឹកគេកាត់លើកមុនវានៅសល់នោះនៅខ្ទុះបន្តិចបន្តួចហើយវ៉ៃចូលមកក្នុងហ្នឹង ។

វណ្ណៈ   បាទ ។

ឡាំង ៖ គ្រាន់ហូរផុតអស់ហើយពេទ្យវាមកច្របាច់មើលហើយយើងហ៊ានបើកខ្លួនឯងត្រូវមាត់វាទៀតហើយពេទ្យបំរើនៅហ្នឹងក៏បើកមិនបានដែលវាហាមដាច់ខាតទាល់តែដុកទ័រធំវាមក ។

វណ្ណៈ   ចឹងកាលពូដាច់ជើងពីណាជាអ្នកចេញលុយឲ្យ?

ឡាំង ៖ ខាងរដ្ឋាភិបាលហ្នឹងឯង ។

វណ្ណៈ   ខាងរដ្ឋាភិបាលខ្មែរក្រហមហ្នឹង?

ឡាំងៈ   បាទ ។

វណ្ណៈ  យើងអត់មានត្រូវការចេញលុយអីទេ?

ឡាំងៈ   បាទ!អត់មានចេញលុយទេ ។

វណ្ណៈ   ហ្នឹងព្យាបាលនៅថៃបើព្យាបាលនៅតាមពេទ្យក្នុងព្រៃរុកយកតែម្តង?

ឡាំង ៖ ស្រែកហើយ  យើងនៅបច្ចេកទេសនៅអន់ជាងគេ  និយាយយើងមិនសូវមានថវិការខ្ពស់ ។

វណ្ណៈ   ចឹងពេលកាត់មានថ្នាំស្ពឹកទេ?

ឡាំង ៖ ពេលកាត់មានថ្នាំស្ពឹក  តែកាត់ហើយយើងត្រូវលាងមុខរបួសពេលហ្នឹងអត់មានថ្នាំស្ពឹកទេ  គេលាងធម្មតា ។

វណ្ណៈ   ចឹងពូគិតថាម៉ាឡៃពីមុនហើយឥឡូវមានលក្ខណៈខុសប្លែកគ្នាយ៉ាងម៉េចដែរ?

ឡាំង ៖ ខុសប្លែកច្រើន ។

វណ្ណៈ   ខុសប្លែកយ៉ាងម៉េចខ្លះទៅ?

ឡាំង ៖ ខុសប្លែកទី១ យើងរកបានអីបានខ្លះ ។

វណ្ណៈ   បាទ ។

ឡាំង ៖ ហើយជីវភាពយើងមានដីច្បាស់លាស់ខ្លួនឯងចឹងទៅពីមុនមិនដឹងដីកន្លែងណាដែលហ្នឹង ពីមុនយើងធ្វើមិនច្បាស់លាស់ ជួនកាលកំពង់តែធ្វើប៉ះក្តុង១មកក៏រត់ចឹងទៅ ។

វណ្ណៈ បាទ ។

ឡាំង ៖ តែឥឡូវអត់ទេ យើងចាប់កន្លែងណាបានយើងធ្វើកន្លែងហ្នឹង ។

វណ្ណៈ ហើយមានភូមិឃុំ?

ឡាំង ៖ បាទ!មានភូមិឃុំគេគ្រប់គ្រងចឹងទៅ ។

វណ្ណៈ ចឹងនៅស្រុកម៉ាឡៃនេះមានប៉ុន្មានឃុំពូមានដឹងទេ?

ឡាំង ៖ ខ្ញុំមិនសូវដឹងទេ តែគេចាត់ចែងភូមិឃុំច្បាស់លាស់ នៅកន្លែងនេះលើកមុនមិនដឹងជាភូមិអីផង ។

វណ្ណៈ បាទ ។

ឡាំង ៖ ឥឡូវខ្ញុំដឹងភូមិ ឃុំ ដឹងស្រុក លើកមុនមិនបានដឹងទេ មានជំទប់ទី១ដើម្បីគ្រប់គ្រងមិនចឹង ។

វណ្ណៈ បាទ ។

ឡាំង៖ គ្រប់គ្រងធ្វើកន្លែងនេះកន្លែងនោះចឹងទៅ ដាក់ភូមិកន្លែងនេះភូមិកន្លែងនោះអត់ទេ ។

វណ្ណៈ ចឹងកាលសម្តេចសីហនុចុះមកជិះដំរីអីហ្នឹងនៅមានយួនអីនៅវៃគ្នា?

ឡាំង ៖ មាន ។

វណ្ណៈ តែពូមិនបានចាំឆ្នាំ?

ឡាំង ៖ បាទ!មិនបានចាំឆ្នាំ ។

វណ្ណៈ ចឹងខ្ញុំចង់សួរបកទៅក្នុងសម័យខ្មែរក្រហមវិញ តើពូរស់នៅភូមិឃុំណាដែរ?

ឡាំង ៖ ជំនាន់ខ្មែរក្រហមនៅហ្នឹងដែរ ។

វណ្ណៈ នៅតាគង់?

ឡាំង៖ ម៉ាជំនាន់ហ្នឹងខ្ញុំ ។

វណ្ណៈ ជំនាន់៧៥ដល់៧៩?

ឡាំង ៖ កាលនោះគេជម្លៀសខ្ញុំទៅហើយ ។

វណ្ណៈ ជម្លៀសទៅណា?

ឡាំង ៖ ជម្លៀសខ្ញុំទៅភូមិក្នុងគេហៅជ្រោយស្តៅនោះណាស់ ជ្រោយមេ្ទស ។

វណ្ណៈ ចឹងកាលហ្នឹងពូជម្លៀសទៅជ្រោយស្តៅជ្រោយមេ្ទសហ្នឹងទៅខេត្តបាត់ដំបងដែរ?

ឡាំង ៖ ហ្នឹងហើយនៅខេត្តបាត់ដំបង ។

វណ្ណៈ ចឹងដូចថាពូចេញពីឪពុកម្តាយទៅធ្វើកងចល័តសម័យនោះគេមកហៅពូឬក៏ពូស្ម័គ្រចិត្ត?

ឡាំង ៖ កាលហ្នឹងអត់មានស្ម័គ្រទេគេហៅឲ្យទៅចូលកងចល័តតែម្តង ។

វណ្ណៈ  កាលហ្នឹងពូអាយុប្រហែលជាប៉ុន្មាននៅក្មេងទេ?

ឡាំង ៖ កាលហ្នឹងអាយុប្រហែលជា១៨កាលហ្នឹង ។

វណ្ណៈ  ចឹងកាលឆ្នាំណាពូកាលហ្នឹង  មើលខ្មែរក្រហមចលនាយូរហើយឆ្នាំរដ្ឋប្រហារឆ្នាំ៧០អីហើយចឹងនៅពេលពូចូលទៅកងចល័តអីចឹង ចឹងពូចូលនៅឆ្នាំណាដែរ?

ឡាំងៈ  កាលនោះឆ្នាំ៧៩គេកំពង់តែគគ្រឹកគគ្រេងហើយណាស់ ។

វណ្ណៈ  ៧៩វៀតណាមវាចូលមកហើយ  តែខ្ញុំចង់និយាយបកទៅសួររឿងរ៉ាវជំនាន់ខ្មែរក្រហមធ្វើអីនៅកន្លែងណាខ្លះដែរចឹងណាស់  ដូចថាឆ្នាំ៧៥ខ្មែរក្រហមកាន់កាប់ហើយ  ចឹងកាល៧៥ហ្នឹងពូនៅណាដែរ?

ឡាំង ៖ កាល៧៥គេជម្លៀសចេញពីក្នុងភូមិមកហើយ ។

វណ្ណៈ  ជម្លៀសចេញទៅនៅណា?

ឡាំង ៖ខ្ញុំទៅនៅអីគេហៅជ្រោយស្ដៅ ។

វណ្ណៈ  ជ្រោយស្ដៅហ្នឹងនៅស្រុកអីកាលហ្នឹង?

ឡាំង ៖ ស្រុកថ្មគោលដឹង  ជិតថ្មលគោលហ្នឹងដែរ ។

វណ្ណៈ  ហើយឆ្នាំណាពូចេញពីឪពុកម្ដាយទៅកងចល័ត?

ឡាំង ៖ គ្រាន់តែទៅដល់កន្លែងហ្នឹងគេឲ្យចេញទៅកងចល័តតែម្ដង  គេមិនឲ្យនៅទេ ។

វណ្ណៈ  ចូលកងចល័តហ្នឹងគេឲ្យធ្វើអីទៀត?

ឡាំង ៖ គេឲ្យដូចជាការងារអីជាច្រូតស្រូវស្ទូងដកចឹងទៅណាស់  បន្ទាប់មកបានគេហៅទៅឲ្យលើកដីធ្វើអាងកំពីងពួយនោះណាស់ ។

វណ្ណៈ  ធ្វើនៅអាងកំពីងពួយហ្នឹងយ៉ាងម៉េចទៀតពូ?

ឡាំង ៖ ដល់ហើយគេឲ្យខ្ញុំទៅយកខោអាវខ្សារាប់និងស៊ីម៉ង់ស្សតិនៅដេកយើងអីខេត្តបាត់ដំបងនោះ ។

វណ្ណៈ  ចឹងបន្ទាប់មកទៀត?

ឡាំង ៖ បន្ទាប់មកទៀត  ខ្ញុំវិលមកវិញមកវែកដីដែរ  គេប្រើឲ្យខ្ញុំទៅដឹកទឹកឲ្យគេដឹកចឹងទៅ ។

វណ្ណៈ  បាទ ។

ឡាំង ៖ បន្ទាប់មកទៀតខ្ញុំមកចូលកងហ្នឹងទៅជួបការលំបាកហើយបានគេឲ្យខ្ញុំដើរជ្រលក់ខោអាវលិចកើតចឹងទៅណាស់ ។

វណ្ណៈ  បាទ!ជ្រលក់ខោអាវឲ្យប្រជាជន?

ឡាំង ៖ ប្រជាជនអីឲ្យអ្នកកងចល័តធម្មតាហ្នឹង  ទៅជ្រលក់នៅអន្លង់ស្វាយឯណោះ  ជ្រលក់ទៅខ្ញុំនិយាយរឿងខ្ញុំឲ្យអស់ណាស់ ។

វណ្ណៈ  បាទ ។

ឡាំង ៖ ខ្ញុំទៅដល់កន្លែងហ្នឹងទៅមានមិត្តភក្តិខ្ញុំឈ្មោះ អាសារឿន។ ហ្នឹងលួចល្មោភគេហ្នឹង ។

វណ្ណៈ  បាទ ។

ឡាំង ៖ លួចល្មោភគេមករួចគេចាប់យកទៅធ្វើបាបគេដាក់ឃុំឃាំងប៉ុន្មានយប់  វាថាខ្ញុំមិនរស់ទេមើលទៅ ខ្ញុំងាប់ដោយសារល្មោភមួយហើយ ខ្ញុំមិនបានលួចផងពួកម៉ាក់ខ្ញុំនោះណាស់ ។

វណ្ណៈ  បាទ ។

ឡាំង ៖ គេយកមកដាក់មេទ្រុញថាប្តេជ្ញាកំទេច  ខ្ញុំថាងាប់ហើយអ្នកលួចហ្នឹងគេយកទៅវៃចោលនៅតែខ្ញុំ មិនបានលួច ខ្ញុំថាឯងយកពីណាមកវាថាអញសុំគេ តែមានអីណាគេតាមមកចាប់កឹប។ ។

វណ្ណៈ  បាទ ។

ឡាំង ៖ចាប់ភ្លាមហ្នឹង ។

វណ្ណៈ  ចឹងកាលពូនៅកងចល័តការហូបចុកលំបាកឬមិនលំបាកទេ?

ឡាំង ៖ លំបាកណាស់  ហូបបបរវាវក្រខ្វក់និយាយរួមខ្ញុំឈឺបានចុះឡើង។ បានគេឲ្យខ្ញុំមកធ្វើការនៅជិត មកតាហែនមកធ្វើសំណង់ជាមួយគេហ្នឹង ខ្ញុំរៀនបើកឡានម៉ៃខូកាយដីលិចកើតហ្នឹងណាស់ ។

វណ្ណៈ  ចឹងជំនាន់ខ្មែរក្រហមមានម៉ៃខូអីដែរ?

ឡាំង ៖ មានគេកាយធ្វើប្រឡាយអីហ្នឹងណាស់  កាលជំនាន់ហ្នឹងខ្ញុំរៀនមិនចេះ  ទៅរៀនអាសម្រាប់ចូក មកលាយខ្សាច់និងស៊ីម៉ង់រុតិហ្នឹង ។

វណ្ណៈ  ធ្វើចឹងគេហៅថាកងវិស្វកម្មអីហ្នឹង?

ឡាំង ៖ ហ្នឹងគេហៅថាកងវិស្វកម្មនិងហើយតែជំនាន់ហ្នឹងគេហៅកងចល័ត ។

វណ្ណៈ  ចឹងជាកងទ័ពដែរ?

ឡាំង ៖ មិនមែនជាកងទ័ពទេ ជាកងចល័ត យើងចល័តទៅខាងនេះក៏បានទៅខាងនោះក៏បានចឹងទៅ ។

វណ្ណៈ  បាទ ។

ឡាំង ៖ ដល់ពេលនេះគេថា  មានពីណាចង់ទៅលេងជាមួយបងប្អូនក៏ទៅ។ ពីណាទៅជួបជុំបងប្អូនក៏ទៅ។ គេអត់មានឃាត់ទេណាស់ ។

វណ្ណៈ  បាទ ។

ឡាំង ៖ គេធ្វើសំបុត្រឲ្យតែគេថាទៅលេងបងប្អូនគេមិនឲ្យមកវិញទេ បើថានៅលេងបងប្អូនគេមិនឲ្យមក កន្លែងកងវិញទេខ្ញុំថាមិនដែលបានទៅលេងបងប្អូនផងទៅហើយ ។

វណ្ណៈ  ចឹងពូទៅហើយមិនមកកន្លែងកងវិញទេ?

ឡាំង ៖ អត់ទេ គេមិនឲ្យចូលគេថាដាច់ខាតគេមិនឲ្យចូលទេ ។

វណ្ណៈ  ចឹងហេតុអីបានជាគេមិនឲ្យយើងចូលកងវិញ?

ឡាំង ៈ ដល់គេមិនឲ្យចូលហើយខ្ញុំចាប់ផ្ដើមមកនៅព្រៃលាវ  នៅកងចល័តព្រៃលាវណាស់គេឲ្យធ្វើជីយកអាចម៍មនុស្សយើងហ្នឹងលាយជាមួយស្លឹកៗហ្នឹងខ្ញុំធ្វើមិនកើត  ខ្ញុំធ្វើមិនកើតគេឲ្យខ្ញុំទៅដាំស្ពៃឲ្យគេហូប ។

វណ្ណៈ  បាទ ។

ឡាំង ៈ ខ្ញុំនៅកន្លែងដាំស្ពៃលិចកើតហើយដល់ពេលនេះហេវជ្រីង  ឡើងទៅលើចុងដូងហ្នឹងបាញ់ជ្រីងបានមួយឡើងទៅអត់មានពុកប៉ុស្ដិផ្សាយតែពុត្រឹមៗចឹងខ្ញុំថាពួកនេះផ្ដាច់ប៉ុស្ដិអីចឹង  កាលហ្នឹងយួនបុកមកហើយ ។

វណ្ណៈ  បាទ ។

ឡាំង ៈ ខ្ញុំថាដាច់ប៉ុស្ដិអត់មានពុផ្សាយអីចឹង  គេថាមិនអីទេ  គេឃោសនាឲ្យយើងនៅហ្នឹងកុំឲ្យយើងភ័យ ។

វណ្ណៈ  បាទ ។

ឡាំង ៈ ចេះតែពុខ្លាំងឡើងៗរហូតដល់ឆ្ងាយបាត់ដំបង  ឡានយួនវែងមកបរិលយើងនេះ  ពួកយោធាគេហ្នឹងខ្ញុំមិនទាន់ជាយោធានិងគេទេ ។

វណ្ណៈ  បាទ ។

ឡាំង ៈ គេថាមិនបានទេ  ឯងតែចូលទៅយួនអាករធាងត្នោត  ខ្ញុំក៏វាឆោតដែរ ។

វណ្ណៈ  ចឹងកាលហ្នឹងពូខ្លាចអីបើយើងមិនបានធ្វើអីផងកាលជំនាន់ហ្នឹងយើងនៅកងចល័តរហូតហ្នឹង?

ឡាំង ៈ ចឹងបានថាខ្ញុំឆោតហ្នឹង  បើដឹងទៅមកបងប្អូនបាត់ហើយ  ចឹងខ្ញុំមករហូតឆ្ងាយព្រំដែនហ្នឹងឯង ។

វណ្ណៈ  ចឹងកាលហ្នឹងពូជឿថាប្រជាជនស្លាប់ដោយអត់បាយឬគេយកទៅសម្លាប់ចោលទេពូជឿទេ?

ឡាំង ៈ ខ្ញុំដូចជាមានខ្លះម៉ាជំនាន់ខ្ញុំរត់មកហ្នឹង  ខ្លះដាច់បាយខ្លះសម្រេចបានវានៅកាកសំណល់ខ្លះ  កាលជំនាន់មានខ្លះតាមមើលទៅ  ខ្ញុំដេកមើលទៅឃើញគេយកមកយកអីណាស់  តែមិនដឹងថាគេយកមកពីកន្លែងណាទេ  ខ្ញុំទៅហ្នឹងឃើញមានខ្លះ  ដល់ក្រោយៗមកទៀតអត់ទេ ។

វណ្ណៈ  បាទ ។

ឡាំង ៈ ធម្មតាដល់ក្រោយមកទៀតគេប្រមូលផ្ដុំកំលាំងមិនចែកចាយទៅណាទេ  ព្រោះវាខ្វះកំលាំងហើយគេត្រូវតែធ្វើចឹង ។

វណ្ណៈ  ចឹងពូមានជឿថាប្រជាជនស្លាប់ច្រើនទេ  នៅក្នុងសម័យបីឆ្នាំ?

ឡាំង ៈ យី!ស្លាប់ច្រើន ។

វណ្ណៈ  ចឹងពូគិតថាការស្លាប់របស់ប្រជាជនហ្នឹងពូគិតថាមកពីថ្នាក់ក្រោមឬមកថ្នាក់លើ  នេះជាគំនិតរបស់ពូ?

ឡាំង ៖ ខ្ញុំវិញ ខ្ញុំថាអ្នកក្រោមអ្នកកណ្ដាល អ្នកអនុវត្តន៍ក្រោមៗមកទៀត ខ្លះត្រឹមមេក្រុមអាចសម្រេចបានដែរ ។

វណ្ណៈ ហេតុអីបានជាចឹង?

ឡាំង ៖ ចឹងបានថា ខ្ញុំមិនដឹងហេតុអីខ្ញុំមិនហ៊ានសន្និដ្ឋានដែរ បើតាមគេនិយាយថាអ្នកនយោបាយខ្មែរក្រហមគាត់និយាយ នយោបាយទី១មយ៉ាងមិនមែនគាត់ធ្វើផ្ទាល់ទេមានអ្នកមកពីក្រោយៗហ្នឹងមានខ្មែរយៈគេហៅសេអ៊ីអារបស់យួនទេ គេនិយាយចឹងណាស់ ។

វណ្ណៈ បាទ!ពីណាជាអ្នកនិយាយចឹង?

ឡាំង ៖ អ្នកដែលគេគ្រប់គ្រងនៅម៉ាឡៃហ្នឹង មេខ្មែរក្រហមតែម្ដង ។

វណ្ណៈ គាត់ឈ្មោះអី?

ឡាំង ៖ គាត់ឈ្មោះហន ។

វណ្ណៈ ចឹងគាត់ថាប្រជាជនស្លាប់ច្រើននៅក្នុងសម័យប៉ុល ពតហ្នឹងដោយសារខ្មែរសេអ៊ីអាយួន?

ឡាំង ៖ បាទ!មានខ្មែរសេអ៊ីអាយួនមកបន្កប់ឲ្យខ្មែរនិងខ្មែរវៃគ្នាចោលទៅ ។

វណ្ណៈ គាត់មានឋានៈអីដែរ?

ឡាំង ៖ គាត់ត្រឹមថ្នាក់ប្រធានវរៈសេនាធំ ពីមុនគាត់នៅខាងស្រុកអី ។

វណ្ណៈ គាត់ប្រជាជននៅម៉ាឡៃ?

ឡាំងៈ អត់ទេ កាលនោះជំនាន់យើង៧៩ហ្នឹងមក គាត់នៅស្រុកដល់រត់ចេញយួនចូលមកហ្នឹងគាត់នៅខាងទ័ព ។

វណ្ណៈ ចឹងគាត់ថាប្រជាជនស្លាប់ជំនាន់បីឆ្នាំហ្នឹងជាខ្មែរសេអ៊ីយួន គេថាចឹង?

ឡាំង ៖ បាទ ។

វណ្ណៈ ថាជាខ្មែរបន្កប់?

ឡាំងៈ ថាឲ្យខ្មែរវៃខ្មែរឲ្យអស់ទៅស្រួលវាគ្រប់គ្រង ។

វណ្ណៈ ចឹងថ្នាក់ដឹកនាំខាងលើដូចតា ខៀវ សំផន តា នួន ជាគាត់ធ្លាប់និយាយបែបហ្នឹងទេ?

ឡាំង ៖ គាត់អត់មាននិយាយចឹងទេ ។

វណ្ណៈ ចឹងពូគិតថាពួកគាត់យ៉ាងម៉េចដែរ ពួកគាត់គ្រប់គ្រងប្រទេសទាំងមូលហើយមានប្រជាជនស្លាប់ច្រើនចឹង ពូថាពួកគាត់បានដឹងរឿងហ្នឹងទេ?

ឡាំង ៖ រឿងគាត់ដឹង រឿងគេក្រឡៃគាត់ក៏បានមិនសូវដឹងរឿងហ្នឹងប៉ុន្មានទេ ។

វណ្ណៈ ចឹងពូគិតថា ខៀវ សំផន នួន ជាមិនសូវដឹងរឿងហ្នឹងទេ?

ឡាំង ៖ ហ្នឹងហើយនេះតាមគំនិតខ្ញុំទេ តាមខ្ញុំមើលថ្នាក់ៗមកហ្នឹង ។

វណ្ណៈ  ចឹងពូគិតថាពួកគាត់មិនសូវបានដឹងទេ?

ឡាំង ៖ បាទ ។

វណ្ណៈ  ចឹងជាគំនិតពូផ្ទាល់មតិរបស់ពូទេណាស់ ពូចង់និយាយយ៉ាងម៉េចក៏បានក្នុងគំនិតរបស់ពីចេញមតិផ្ទាល់ពូកុំទីសទាល់ឬក៏យ៉ាងម៉េច ចឹងដូចថា ដូចថាឥឡូវហ្នឹងប្រទេសយើងស្លាប់ប្រជាជន ច្រើនពេកបើគិតទៅប្រទេសយើងតូចមានប្រជាជនតែប៉ុន្មានលាននាក់ ហើយស្លាប់មនុស្សជាងមួយលាននាក់ ។

ឡាំង ៖ បាទ ។

វណ្ណៈ  កាលឆ្នាំ៧៩ យើងថាអស់ជាងបីលាននាក់អស់ជាងពាក់កណ្តាល ចឹងតាមការស្រាវជ្រាវផ្សេងៗបញ្ជាក់ថាអស់ជាងមួយលាននាក់ គិតថាមិនច្រើន តែប្រទេសគេផ្សេងស្លាប់អស់ច្រើនលាននាក់សម្រាប់ប្រជាជនគេមានច្រើនលាននាក់ បើប្រៀបធៀបជាមួយប្រទេសគេយើងស្លាប់ច្រើនជាងវិញ ។

ឡាំង ៖ បាទ ។

វណ្ណៈ  ចឹងបានជាមានអង្គការសហប្រជាជាតិតម្រូវឲ្យមានការកាត់ទោស អ្នកដែលប្រព្រឹត្តខុសមកលើប្រជាជនខ្លួនឯងឬសាសន៍ដទៃអីក៏ដោយ ។

ឡាំង ៖ បាទ ។

វណ្ណៈ  ចឹងពូគិតថាតុលាការសព្វថ្ងៃហ្នឹង ពូគាំទ្រឲ្យមានតុលាការហ្នឹងដែលអត់ឬមួយពូគិតថាធ្វើចឹងមិនត្រឹមត្រូវទេពូគិតថាម៉េច?

ឡាំង ៖ ទេ ខ្ញុំគិតថាវាត្រឹមត្រូវម្យ៉ាងដែរ ដើម្បីឲ្យដឹង ។

វណ្ណៈ  ចឹងពូគិតថាមានតុលាការជាការត្រឹមត្រូវហើយ?

ឡាំង៖  បាទ ។

វណ្ណៈ  ចឹងសព្វថ្ងៃហ្នឹងតុលាការបានឃុំខ្លួនអៀង សារី ប្រពន្ធអៀង សារី ខៀវ សំផនទាំងអស់ហ្នឹងពូគិតថាជាការឃុំខ្លួនរបស់តុលាការហ្នឹងត្រឹមត្រូវឬមិនត្រឹមត្រូវ?

ឡាំង ៖ ទេ អារឿងហ្នឹងខ្ញុំពិបាកថាដែរ ។

វណ្ណៈ  ចឹងពីមិនអាចថាបានទេ?

ឡាំង៖  បាទ! ខ្ញុំមិនសូវដឹងរឿងដែរ ។

វណ្ណៈ  ចឹងបើចិត្តពូវិញគិតថាមិនត្រូវមានតុលាការឬត្រូវតែមាន?

ឡាំង ៖ ទេ អារឿងហ្នឹងវាត្រូវតែមានហើយ ។

វណ្ណៈ  ចឹងត្រូវតែមាន?

ឡាំង ៖ បាទ! តុលាការជាអ្នកវិនិច្ឆ័យច្បាប់ អ្នកណាធ្វើខុសត្រូវទទួលកំហុស ចឹងបើអត់មានអាហ្នឹងទេ មនុស្សចេះតែប្រព្រឹត្ត ។

វណ្ណៈ ចឹងពូប្រៀបធៀបមើលការរស់នៅជំនាន់ខ្មែរក្រហមនិងឥឡូវមានលក្ខណៈខុសគ្នាបែបយ៉ាងម៉េច?

ឡាំង ៖ វាមយ៉ាងម្នាក់ ។

វណ្ណៈ មយ៉ាងម្នាក់យ៉ាងម៉េច?

ឡាំង ៖ មយ៉ាងទី១ នៅជំនាន់ខ្មែរក្រហមដឹងថាតឹងស្អាតតែម្តង ហើយមនុស្សក៏គោរពបានស្អាតដែរ មិនពិបាកទេ តែអ្នកគោរពមិនបានគឺពិបាកណាស់ ។

វណ្ណៈ ចឹងច្បាប់ខ្មែរក្រហមល្អ?

ឡាំង ៖ មិនថាជាល្អទេ តែមនុស្សគោរពបានមនុស្សហ្នឹងវាល្អដែរ អ្នកដែលខូចផ្សេងៗថាច្បាប់និងតឹងតែងសំបើមណាស់ ។

វណ្ណៈ ឥឡូវខ្ញុំចង់ដឹងពូខ្មែរក្រហមមានចំណុចល្អប៉ុន្មានច្បាប់គោរពវិន័យល្អ?

ឡាំង ៖ ល្អមយ៉ាងអត់មានចោរ ។

វណ្ណៈ មានអីទៀត?

ឡាំង ៖ មយ៉ាងយើងធ្វើអីឲ្យបានពិតប្រាកដ អត់មានចង់សូកប៉ុននេះចង់សូកប៉ុននោះបានតាមចិត្តទេណាស់ ហ្នឹងអត់បានទេ ។

វណ្ណៈ បាទ ។

ឡាំង ៖ អាហ្នឹងច្បាស់លាស់តែម្តង ណែឯងចង់សូកប៉ុណ្ណោះសូកប៉ុននេះមិនបានទេ ។

វណ្ណៈ ចឹងមានីទៀតដែលល្អរបស់ខ្មែរក្រហម?

ឡាំង ៖ ល្អមានឃើញតែប៉ុណ្ណឹង ។

វណ្ណៈ ចឹងចំណុចអាក្រក់?

ឡាំង ៖ មានអាក្រក់ច្រើន ចុះច្បាប់វាតឹងរឹងពេកខ្ញុំម៉ាជំនាន់ ប៉ុន្មានជិតមួយឆ្នាំមិនបានជួបប្រពន្ធម្តង ។

វណ្ណៈ និយាយជំនាន់ខ្មែរក្រហមពីឆ្នាំ៧៥ដល់៧៩ហ្នឹង?

ឡាំងៈ និយាយជំនាន់ខ្មែរក្រហមហ្នឹង ។

វណ្ណៈ ហ្នឹងហើយខ្មែរក្រហមមានចំណុចអាក្រក់ស្អីខ្លះ?

ឡាំង ៖ មានច្រើន វៃមនុស្សចោលច្រើន ។

វណ្ណៈ ចឹងបើនិយាយពីច្បាប់អត់មានចោរអត់ពុករលួយនៅជំនាន់៧៥ដល់៧៩ណាស់?

ឡាំងៈ បាទ! ហើយអត់មានលុយចាយយ៉ាប់ដែរ ។

វណ្ណៈ ចឹងគឺងតែងរើមនុស្សចោលអាហ្នឹងចំណុចអាក្រក់របស់ខ្មែរក្រហម?

ឡាំងៈ បាទ ។

វណ្ណៈ អត់លុយចាយយ៉ាងម៉េចទៀត?

ឡាំង ៈ អត់លុយចាយហើយម្យ៉ាង ធ្វើការទាំងយប់ទាំងថ្ងៃទៀត ហើយអត់មានម្ហូបស៊ីគ្រប់គ្រាន់ទេ មិនថាយើងខំធ្វើបានស៊ីដូចឥឡូវណា ធ្វើដូចមុនមិនដឹងជាមានប៉ុណ្ណា ។

វណ្ណៈ បាទ ។

ឡាំង ៈ ធ្វើទាំងយប់ទាំងថ្ងៃគ្មានឈប់ឈរបើដូចសព្វថ្ងៃនេះមិនដឹងជាមានប៉ុណ្ណាទេ ។

វណ្ណៈ បាទ ។

ឡាំង ៈ ហើយធ្វើប៉ុណ្ណឹងហើយមិនមានអីស៊ីផង ស្រួលមិនស្រួលគេយកទៅវៃចោលទៀត ។

វណ្ណៈ បាទ ។

ឡាំង ៈ របស់ដែលយើងខំដាំហ្នឹងបើយើងមិនសុំប្រធានភូមិទេ ស្អីគេលិចកើតទេដឹងថាអ្នកឯងដាំអត់មានច្បាប់ទំលាប់អត់មានទៅសុំគេយើងដាំសោះណាស់ យើងដាំក្បែរៗផ្ទះហ្នឹងជំនាន់ម៉ែខ្ញុំគាត់នៅធ្វើនេសាទហ្នឹងដាំក្បែរផ្ទះហ្នឹងខ្ញុំទៅលេងម៉ាជំនាន់ទៅលេងនោះណាស់ ។

វណ្ណៈ បាទ ។

ឡាំង ៈ ខ្ញុំទៅលេងខ្ញុំថាម៉ែល្ពៅធំៗដល់ហើយ គាត់ថាទាល់ទៅសុំគេបាន យើងដាំមែនទាល់ទៅសុំគេ ។

វណ្ណៈ ចឹងចំការមីនទាំងអស់ហ្នឹង ដូចជាកន្លែងមានមីនផ្សេងៗហ្នឹងពីខាងណាជាអ្នកដាក់ខ្លះពូ?

ឡាំង ៈ និយាយរួមខាងខ្មែរក្រហមក៏ដាក់ខាងយួនក៏ដាក់ ។

វណ្ណៈ ចឹងដាក់ទាំងអស់គ្នា?

ឡាំងៈ បាទ!និយាយរួមវាបី ។

វណ្ណៈ បីមានពីណាខ្លះ?

ឡាំង ៈ ទី១ ខ្មែរក្រហម ។

វណ្ណៈ បាទ ។

ឡាំងៈ ទី២ទាហានខ្មែរយើងណាស់ ។

វណ្ណៈ បាទ ។

ឡាំងៈ ទី៣ទាហានយួនតែម្តង ។

វណ្ណៈ បាទ ។

ឡាំងៈ ទី១ម្យ៉ាងវាមិនមែនត្រឹមបីទេវាដាក់ហ្នឹងគ្រប់គ្រងកន្លែងហ្នឹងទី១យួនមកដាក់មុនដំបូងក្រោយមកទៀតបានទាហានខ្មែរយើងហ្នឹងរាយព្រំរបងតាមហ្នឹងទៀតតាមព្រំដែនហ្នឹងណាស់ ។

វណ្ណៈ   បាទ ។

ឡាំងៈ   យើងធម្មតាខ្មែរក្រហមចេញចូលចុះឡើងខ្មែរក្រហមនិងដាក់មួយសារទៀត ។

វណ្ណៈ   បាទ ។

ឡាំង ៖ វាពីរបីដំណាក់ចឹងបានជាមីនច្រើនណាស់  មានអ្នកដាច់ដៃដាច់ជើងច្រើនចឹងឯង  ជួនណាដាក់ខ្លួនឯងដាន់ខ្លួនឯងទៀត ។

វណ្ណៈ   ចឹងខ្ញុំដូចជាអស់សំនួរសួរពូហើយ  តើពូមានចង់សួរអីថែមទៀត?

ឡាំង ៖ អត់មានចង់និយាយអីទៀតទេ ។

វណ្ណៈ   ចឹងខ្ញុំអរគុណពូច្រើនហើយដែលបានផ្តល់បទសម្ភាសន៍ដែលទាក់ទងនៅក្នុងសម័យខ្មែរក្រហម ។

ឡាំង ៖ បាទ ។

**«ចប់»**